


ទាណីបន

# អក្សរសិល្ប៍ខ្មែរសតវត្សទី២០

ឃីង ហុក ឌី

បណ្ឌិតរដ្ឋថ្នាក់អក្សរសាស្ត្រ
និងមនុស្សសាស្ត្រ
អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិ
ស្រាវជ្រាវវិទ្យាសាស្ត្រ
សាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិភាសា
និងអារ្យធម៌បូព៌ា

Éditions de la plus haute tour

# KHING HOC DY
# Anthologie de la littérature khmère du XXe siècle

អក្សរសិល្ប៍ខ្មែរសតវត្សទី២០នេះជាកម្រងអត្ថបទនៃកវីនិពន្ធយើងចាប់ពីឆ្នាំ១៩០០ដល់ឆ្នាំ២០០០ព្រមទាំងបង្ហាញស្រួសៗពីប្រវត្តិអក្សរសិល្ប៍ខ្មែរនៅក្នុងរយៈពេលមួយ សតវត្ស ពោល គឺ ចាប់ តាំង ពី សម័យ អាណានិគម បារាំង រហូត មក ដល់ សម័យនវរាជានិយមសព្វថ្ងៃព្រមទាំងបង្ហាញកវីនិពន្ធសំខាន់ៗក្នុងជំនាន់នីមួយៗភ្ជាប់នឹងអត្ថបទដកស្រង់គោលៗរបស់កវីនិពន្ធទាំងនោះ។ ស្នាដៃនេះជាកម្រងមាលាអក្សរសិល្ប៍ក្តោបជា ចង្កោម ជាប់ ជា មួយ ប្រវត្តិ អក្សរសិល្ប៍ យើង នៃ សតវត្សដែល ទើប នឹង កន្លង ទៅ ថ្មីៗនេះ។ សៀវភៅនេះសង្ឃឹម ថា នឹង អាច ទុក ជា ឧបករណ៍ ជំនួយ មួយ ដល់ សិស្ស-និស្សិត, លោកគ្រូអ្នកគ្រូនិងសាស្ត្រាចារ្យក្នុងការសិក្សាស្រាវជ្រាវពីអក្សរសិល្ប៍ខ្មែរទៅថ្ងៃក្រោយ។ អក្សរសិល្ប៍ខ្មែរសតវត្សទី២០នេះគឺជាភាគ១នៃកម្រងអក្សរសិល្ប៍ខ្មែរនេះហើយនឹងមានបោះពុម្ព ចេញ ផ្សាយ ទៅ ថ្ងៃ ក្រោយ នូវ អក្សរសិល្ប៍ ខ្មែរ សតវត្ស ទី ១៩, ទី ១៨, ទី ១៧ ។ល។ ជាបន្តបន្ទាប់ទៅទៀត។

ឃីង ហុកឌី កើត ថ្ងៃ ទី ១៣ មិថុនា ១៩៤៤ ក្នុង ស្រុក ស្ទោង ខេត្ត កំពង់ធំ, ជា អតីតនិស្សិត មហាវិទ្យាល័យ គរុកោសល្យ និង អតីត សិស្ស សាលា គរុវិជ្ជា ជាន់ ខ្ពស់ ភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ បានទទួលដំណែងជាសាស្ត្រាចារ្យទុតិយភូមិផ្នែកអក្សរសាស្ត្រខ្មែរនៅខេត្តកំពង់ស្ពឺជាដំបូងរួចមកនៅទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧១បានមកបន្តវិជ្ជានៅក្រុងប៉ារីសហើយបានបញ្ចប់និក្ខេបបទបណ្ឌិតតតិយភូមិនៅសកលវិទ្យាល័យសរ័បោនប៉ារីសទី៣នៅឆ្នាំ១៩៧៤។ ឆ្នាំ ១៩៧៤-១៩៨៤ បានធ្វើ ការ ជា អភិរក្ស ជំនួយ នៅ សារៈមន្ទីរមនុស្ស ក្រុងប៉ារីស។ ចាប់ពីខែវិច្ឆិកា១៩៨៤លោកបានប្រលងជាប់ ចូល ក្នុងមជ្ឈមណ្ឌល ជាតិ ស្រាវជ្រាវវិទ្យាសាស្ត្រ ហើយ បានទទួល ដំណែងជាអ្នកទទួល បន្ទុកស្រាវជ្រាវហើយក្នុងរយៈពេលដដែលនេះ បាន ធ្វើ ការ បន្ថែម ជា សាស្ត្រាចារ្យ ជំនួយ នៅវិទ្យាស្ថាន ជាតិ ភាសា និង អរិយធម៌ បូព៌ាប្រទេស។ នៅ ឆ្នាំ ១៩៩៣ បាន បញ្ចប់ និក្ខេបបទ បណ្ឌិត រដ្ឋ ផ្នែក អក្សរសាស្ត្រ និងមនុស្សសាស្ត្រនៅសកលវិទ្យាល័យសរ័បោនដដែល ហើយ នៅឆ្នាំ១៩៩៨បានទទួលសញ្ញាប័ត្រនីតិសម្បទា (habititation à diriger des recherches) ដោយ មានតួនាទីដឹកនាំនិស្សិតថ្នាក់បណ្ឌិតផ្នែក អក្សរសាស្ត្រ ខ្មែរ នៅវិទ្យាស្ថាន ភាសា និង អរិយធម៌បូព៌ាប្រទេស។ ស្នាដៃ លោក ជាច្រើន ស្តី ពី អក្សរសាស្ត្រ ខ្មែរ បាន បោះ ពុម្ព ផ្សាយ នៅ ប្រទេស បារាំង, អង់គ្លេស, សហរដ្ឋអាមេរិក, រុស្ស៊ី, ចិនប្រជាមានិត, ជប៉ុន, និងសិង្ហបុរីជាដើម។

SIPAR

តំលៃ: ៧៥០០ រៀល

SOLARIS MEDIA GROUP

PHNOM-PENH
Centre Culturel Français